

ត្រូវបានរាប់ជាសុចរិត



Part 7/10
Resurrection
ដោយ ដេរេក ព្រីនស៍

វិសេសណាស់ដែលបានចូលមកជួបជាមួយលោកអ្នកជាថ្មីនៅថ្ងៃនេះ តាមពេលវេលាកំណត់របស់យើង។ សប្តាហ៍នេះ ខ្ញុំកំពុងតែបន្តគោលសំខាន់អំពី «ការរស់ពីឡើងវិញ» ដែលនេះជាព្រះពរមិនអាចវាស់ស្ទង់បាន ដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើង តាមរយៈការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ ម្យ៉ាងមិញ ខ្ញុំបានពន្យល់ពីរបៀបដែលយើងអាចត្រូវបានបង្កើតជាថ្មី ឬកើតជាថ្មី តាមរយៈជំនឿលើការរស់ពីឡើងវិញរបស់ព្រះយេស៊ូវ គ្រីស្ទ។ ខ្ញុំបានដកស្រង់សេចក្តីខ្លះ ចេញពីប្រសាសន៍របស់សាវកពេត្រុស នៅក្នុង១ពេត្រុស ១:៣ ដែលចែងថា:

> «សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឲ្យយើងរាល់គ្នាបានសេចក្តីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ...» (RKOV)

ខ្ញុំបានជម្រាបជូនពីគោលសំខាន់ ដែលយើងបានចាប់ផ្តើមមើលជាមួយគ្នាពីសប្តាហ៍មុន ជាគោលសំខាន់ ដែលយើងមានអត្តសញ្ញាណរួមជាមួយព្រះយេស៊ូវ។ ជាដំបូង ព្រះយេស៊ូវបានដាក់អង្គទ្រង់រួមជាមួយយើង ចូលមកទទួលទោសកំហុសរបស់យើង ហើយដោយការសុគតរបស់ព្រះអង្គ ព្រះអង្គបានបង់ថ្លៃពិន័យទោសសម្រាប់អំពើបាបរបស់យើង។ បន្ទាប់មក នៅពេលយើងទទួលយកអត្តសញ្ញាណរួមជាមួយព្រះអង្គដោយជំនឿ ហើយមធ្យោបាយចម្បងរបស់យើងក្នុងការទទួលយកអត្តសញ្ញាណនោះ គឺការជ្រមុជ ដែលបទគម្ពីរចែងថា យើងត្រូវបានបញ្ចុះទៅក្នុងផ្នូរ រួមជាមួយព្រះអង្គដោយការជ្រមុជ។ ក្រោយការនោះមក យើងដើរតាមព្រះ អង្គ គឺយើងត្រូវបាននាំឆ្លងកាត់ជាមួយព្រះអង្គ ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ចូលទៅក្នុងគ្រប់ទាំងការ ដែលកើតមានឡើងតាមក្រោយ គឺចូលទៅក្នុងការរស់ឡើងវិញ និងការលើកឡើងទៅស្ថានសួគ៌។ នៅក្នុងគម្ពីរអេភេសូរ ជំពូក២ លោកប៉ូលមានប្រសាសន៍ថា «ព្រះអង្គបាននប្រោសចាយើងបានរស់រួមជាមួយព្រះគ្រីស្ទ... យើងបានរស់នឡើងវិញរួមជាមួយព្រះគ្រីស្ទ...ហើយឲ្យយើងសោយរាជ្យរួមជាមួយព្រះគ្រីស្ទ...» នោះហើយជាគោល សំខាន់នៃអត្តសញ្ញាណរបស់យើង រួមជាមួយព្រះយេស៊ូវ។ ការដែលបានប្រោសឲ្យរស់រួមជាមួយព្រះអង្គ នោះ យើងត្រូវបានបង្កើតជាថ្មី ឬហៅថា កើតជាថ្មី។ យើងឆ្លងផុតពីប្រព័ន្ធចាស់ និងពីមនុស្សចាស់ ចូលមក ក្នុងប្រព័ន្ធថ្មី ហើយយើងត្រឡប់ជាសមាជិកនៃពូជពង្សថ្មី គឺពូជពង្សអេម៉ាញ៉ូអែល ពូជពង្សដែលព្រះទ្រង់គង់ ជាមួយយើង ជាពូជពង្សដែលមានព្រះយេស៊ូវគ្រីស្ទជាព្រះសិរសា។

នៅថ្ងៃនេះ ខ្ញុំនឹងចែកចាយពីរបៀប ដែលតាមរយៈការរស់ឡើងវិញរបស់ព្រះគ្រីស្ទ យើងអាចត្រូវបានរាប់ ជាសុចរិត នោះគឺ ប្រោសឲ្យបានសុចរិតទាំងស្រុង។ ពាក្យ «ត្រូវបានរាប់ជាសុចរិត» និងពាក្យ «ការរាប់ជា សុចរិត» មានច្រើននៅក្នុងសញ្ញាថ្មី។ ពាក្យទាំងនោះ ជាពាក្យដ៏សំខាន់ ប៉ុន្តែខ្ញុំគិតថាគ្រីស្ទបរិស័ទជាច្រើនមិន បានយល់ពេញលេញពិតប្រាកដ អំពីអត្ថន័យរបស់ពាក្យទាំងនោះនៅឡើយទេ។ ដូច្នេះខ្ញុំសង្ឃឹមថា ពេល លោកអ្នកស្តាប់ការចែកចាយនៅថ្ងៃនេះ លោកអ្នកនឹងយល់បានកាន់តែច្បាស់ ជាងអ្វីដែលលោកអ្នកធ្លាប់គិត ពីមុន អំពីការដែលត្រូវបានរាប់ជាសុចរិត មានន័យដូចម្តេច។

ឥឡូវនេះ គំរូដ៏អស្ចារ្យសម្រាប់យើង ក្នុងនាមជាគ្រីស្ទបរិស័ទដែលកំពុងតែត្រូវបានរាប់ជាសុចរិត ដោយសារជំនឿ គឺត្រូវបានផ្តល់មក ដោយបុព្វបុរសនៃជំនឿរបស់យើង គឺលោកអ័ប្រាហាំ។ នៅក្នុងគម្ពីររ៉ូម ជំពូក៤ លោកប៉ូលនិយាយអំពីឧទាហរណ៍ និងគំរូនៃជំនឿរបស់លោកអ័ប្រាហាំ ហើយបន្ទាប់មក បង្ហាញពី របៀប

ដែលការនេះអនុវត្តចំពោះយើង។ ដូច្នេះ ខ្ញុំនឹងអានសេចក្តីទាំងនេះ នៅក្នុងគម្ពីររ៉ូម ៤:២០-២៥:

> «លោកមិនបានសង្ស័យចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺលោកកាន់តែមានជំនឿ ខ្លាំងឡើង [ឬធ្វើឲ្យលោកកាន់តែខ្លាំង ដោយសារជំនឿរបស់លោក] ហើយថ្វាយសិរីល្អដល់ព្រះ ដោយជឿជាក់អស់ពីចិត្តថា បើព្រះបានសន្យាធ្វើអ្វី នោះព្រះអង្គអាចនឹងសម្រេចបានមិនខាន។ » (RKOV)

តើនេះមិនមែនជាពាក្យដ៏សំខាន់ទេឬ? លោកអ័ប្រាហាំបានជឿទាំងស្រុងថា ព្រះពិតជាមានព្រះចេស្តានឹង ធ្វើតាមអ្វីដែលព្រះអង្គបានសន្យា។ ចុះលោកអ្នកវិញ? តើលោកអ្នកពិតជាជឿជាក់យ៉ាងអស់ពីចិត្តថា ព្រះទ្រង់មានព្រះចេស្តានឹងធ្វើតាមអ្វីដែលព្រះអង្គបានសន្យាឬទេ? បន្ទាប់មក លោកប៉ូលបន្តមានប្រសាសន៍ ហើយលោកដកស្រង់ព្រះបន្ទូលចេញពីគម្ពីរលោកុប្បត្តិ ១៥:៦ ដែលនិយាយអំពីលោកអ័ប្រាហាំថា:

> «ហេតុនេះហើយបានជាជំនឿរបស់លោក ព្រះរាប់លោកជាសុចរិត។[នេះគឺ ដោយការជឿរបស់លោក ធ្វើ ឲ្យព្រះរាប់លោកជាសុចរិត។ បន្ទាប់មក លោកប៉ូល អនុវត្តគំរូរបស់លោកអ័ប្រាហាំមកកាន់យើង ក្នុងនាម ជាអ្នកជឿនៅក្នុងសញ្ញាថ្មី។] ប៉ុន្តែ សេចក្តីដែលបានចែងទុកមកថា ព្រះរាប់លោកជាសុចរិត នេះមិន មែនសម្រាប់តែលោកអ័ប្រាហាំប៉ុណ្ណោះទេ គឺសម្រាប់យើងដែរ។ សេចក្តីនេះនឹងបានរាប់ជាសុចរិតដល់ យើងជាអ្នកជឿដល់ព្រះអង្គ ដែលបានប្រោសព្រះយេស៊ូវ ជាព្រះអម្ចាស់របស់យើង ឲ្យមានព្រះជន្មរស់ពី ស្លាប់ឡើងវិញ។ [សូមកត់សម្គាល់ ប្រសិនបើយើងជឿដោយប្រភេទនៃជំនឿដូចលោកអ័ប្រាហាំដែរ នេះ ក៏នឹងបានសុចរិត ដូចជាអ្វីដែលបានកើតឡើងដល់លោកអ័ប្រាហាំដែរ។ ហើយបន្ទាប់មក លោកប៉ូល សង្ខេបសេចក្តីនេះ នៅក្នុងខ២៥ថា:] ព្រះអង្គ[គឺព្រះយេស៊ូវ] ត្រូវគេបញ្ជូនទៅសម្លាប់ ដោយព្រោះ អំពើរំលងរបស់យើង ហើយព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងបានសុចរិត។» (RKOV)

សូមកត់សម្គាល់ឃ្លាចុងក្រោយ «ព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ឡើងវិញ [ឬថាព្រះអង្គបានរស់ឡើង វិញ] ដើម្បីឲ្យយើងបានសុចរិត។» គឺដើម្បីឲ្យព្រះទ្រង់រាប់ជាសុចរិតដល់យើង។

លោកអ័ប្រាហាំគឺជាគំរូមួយអំពីការបន្តជឿលើសេចក្តីសន្យារបស់ព្រះ ទោះជាមានការបាក់ទឹកចិត្ត ឬអ្វីៗ ដែលហាក់ដូចជាកើតឡើងផ្ទុយក៏ដោយ។ យើងរាល់គ្នា ក្នុងនាមជាគ្រីស្ទបរិស័ទ ត្រូវតែប្រើជំនឿដូចគ្នានេះ ទាក់ទងនឹងការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ ចំពោះអន្តរការណ៍នេះ មានពីរចំណុច។ ទីមួយគឺ ដោយការសុគតរបស់ព្រះគ្រីស្ទ នោះអំពើបាប នឹងថ្លៃពិន័យទោសនៃអំពើបាបរបស់យើងត្រូវបានបង់ថ្លៃពេញលេញ។ ដូច្នេះសេចក្តីយុត្តិធម៌របស់ព្រះ ត្រូវបានបំពេញដោយការសុគតរបស់ព្រះយេស៊ូវ ជំនួសឲ្យយើងរាល់ គ្នា។ ព្រះទ្រង់មិនបង្ខូចសេចក្តីយុត្តិធម៌របស់ព្រះអង្គទេ នៅពេលដែលព្រះអង្គអត់ទោសអំពើបាបរបស់យើង ព្រោះព្រះយេស៊ូវបានបង់ថ្លៃពិន័យទោសយ៉ាងពេញលេញ ក្នុងនាមជាអ្នកតំណាងស្របច្បាប់ដែលព្រះទ្រង់ទទួល យកជំនួសយើង។

ចំណុចទីពីរនៃអន្តរកាណ៍នេះ គឺជាអ្វីដែលចេញពីការរស់ឡើងវិញរបស់ព្រះគ្រិស្ត។ ដោយការរស់ឡើង វិញរបស់ព្រះអង្គ ព្រះគ្រិស្តបានផ្គត់ផ្គង់សេចក្តីសុចរិតយ៉ាងពេញលេញ ពោលគឺ ការរួចផុតពីបន្ទុក ឬការរាប់ថា ជាសុចរិត។ យើងត្រូវបានដោះឲ្យរួចពីបន្ទុកនៃទោសអំពើបាបទាំងអស់។ យើងត្រូវបានរាប់ជាសុចរិត ទទួល ស្គាល់ថាសុចរិត យើងបានទទួលសេចក្តីសុចរិតដ៏ពេញលេញ។ ខ្ញុំចង់សង្កត់ធ្ងន់នូវពាក្យ «ពេញលេញ» ពេញ លេញគឺ៖ មិនមែនខ្លះៗ ប៉ុន្តែពេញលេញទាំងស្រុង។ នេះពិតជាសំខាន់ខ្លាំងណាស់ដែលយើញថា ការរួចពី បន្ទុករបស់យើង គឺអាស្រ័យលើការរស់ឡើងវិញរបស់ព្រះគ្រិស្ត។ នៅក្នុងជំពូកដ៏អស្ចារ្យ ដែលនិយាយពីការរស់ ឡើងវិញ គឺ ១កូរិនថូស ១៥:១៧ លោកប៉ូលប្រកាសសេចក្តីនេះយ៉ាងច្បាស់ថា:

> «ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញទេ នេះជំនឿរបស់អ្នករាល់គ្នា ឥតប្រយោជន៍សោះ អ្នករាល់គ្នានៅ ជាប់ក្នុងអំពើបាបដដែល! » (RKOV)

ការរួចពីបន្ទុករបស់យើង ការរាប់ជាសុចរិតរបស់យើង គឺអាស្រ័យទៅលើការរស់ឡើងវិញរបស់ព្រះ យេស៊ូវ។ លោកអ្នកឃើញហើយ នៅពេលព្រះទ្រង់ប្រោសឲ្យព្រះយេស៊ូវរស់ឡើងវិញ ព្រះទ្រង់ប្រកាសថា ព្រះយេស៊ូវរួចទោសហើយ ព្រោះតុលាការរបស់មនុស្សចំនួនពីរ បានកាត់ទោសប្រហារជីវិតព្រះអង្គរួចហើយ។ តុលាការនោះគឺ តុលាការខាងលោកិយរបស់ចក្រភពរ៉ូមមួយ និងតុលាការនៃក្រុមប្រឹក្សាជាន់ខ្ពស់របស់សាសនា យូដាមួយ។ ដោយការមានព្រះជន្មរស់ឡើងវិញ ព្រះជាម្ចាស់បានបង្វែរសាលក្រមអយុត្តិធម៌ទាំងនោះ ហើយ ប្រកាសថា ព្រះយេស៊ូវទ្រង់សុចរិត។ ប៉ុន្តែ នៅពេលសេក្តីសុចរិតរបស់ព្រះអង្គត្រូវបានប្រកាស នោះក៏មានន័យថា សម្រាប់ជាសេចក្តីសុចរិតរបស់យើងដែរ ព្រោះយើងបានរួមជាមួយព្រះអង្គ នៅក្នុងការរស់ឡើង វិញ។

នៅក្នុង២កូរិនថូស ៥:២១ លោកប៉ូលសង្ខេបសេចក្តីនេះ តាមវិធីមួយដ៏ល្អ នៅពេលដែលលោកថ្លែងថា:

> «ដ្បិត ព្រះគ្រីស្ទ ដែលមិនបានស្គាល់បាប់សោះ តែព្រះបានធ្វើឲ្យព្រះអង្គត្រឡប់ជាតួបាបជំនួសយើង ដើម្បី ឲ្យយើងបានត្រឡប់ជាសេចក្តីសុចរិតរបស់ព្រះ នៅក្នុងព្រះអង្គ។ » (RKOV)

ដូច្នេះ ព្រះយេស៊ូវបានត្រឡប់ជាតួបាប ដោយព្រោះអំពើបាបរបស់យើង ហើយបានបង់ថ្លៃពេញលេញ ជាថ្លៃ ពិន័យទោសសម្រាប់អំពើបាបរបស់យើង ដើម្បីឲ្យយើងបានរួមជាមួយព្រះអង្គ នៅក្នុងសេចក្តីសុចរិត ដែលត្រូវ បានប្រកាស ដោយការរស់ឡើងវិញរបស់ព្រះអង្គ។ ដូច្នេះ យើងបានរាប់ជាសុចរិត គឺត្រឡប់ជាសុចរិតទាំងស្រុង។ ខ្ញុំចូលចិត្តប្រើនិយមន័យតូចមួយអំពីការរាប់ជាសុចរិតនេះ។ ពេលដែលខ្ញុំនិយាយថា ខ្ញុំត្រូវបានរាប់ជាសុចរិត ខ្ញុំចង់និយាយថា ខ្ញុំសុចរិត ហាក់ដូចជាមិនដែលបានធ្វើបាបសោះ ព្រោះការដែលរាប់ថា ខ្ញុំសុចរិតនេះ គឺតាមរយៈការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ជាសេចក្តីសុចរិតមួយដែលមិនដែលស្គាល់បាបសោះ។ ហើយមានតែ សេចក្តីសុចរិតបែបនេះប៉ុណ្ណោះ ដែលស្ថានសួគ៌អាចទទួលយកបាន។

ដូច្នេះ ដោយសារតែការនេះ ត្រូវមានការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ដើម្បីបញ្ជាក់ពីការរួចផុតពីបន្ទុក និងការរាប់ជាសុចរិតដល់យើង នោះតម្រូវឲ្យមានលក្ខខណ្ឌពីរ ប្រកបដោយហេតុផលសម្រាប់យើង ដើម្បីឲ្យ យើងអាចចូលទៅក្នុងសេចក្តី

សង្គ្រោះ។ សេចក្តីនេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយលោកប៉ូល នៅក្នុងគម្ពីរ រ៉ូម ១០:៦-១០:

> តែសេចក្តីសុចរិតដែលមកពីជំនឿ ចែងថា «កុំថាយគិតក្នុងចិត្តថា "នតើអ្នកណានឹងនឡើងនទៅស្ថានសួគ៌"» (គឺ នដើម្បីនាំព្រះគ្រីស្ទចុះមក) «ឬ "នតើអ្នកណានឹងចុះនទៅក្នុងជង្ហុកធាំ"» (គឺនដើម្បីនាំព្រះគ្រីស្ទនឡើងពីពួកមនុស្ស ស្លាប់) នេះនឡើយ។ (RKOV)

អាចនិយាយបានម្យ៉ាងទៀតថា យោងតាមប្រសាសន៍លោកប៉ូល សេចក្តីសុចរិតដែលបានមកពីជំនឿ មិន ត្រូវធ្វើអ្វីដែលព្រះគ្រីស្ទបានធ្វើរួចហើយសម្រាប់យើងនោះទេ ហើយប្រសិនបើយើងព្យាយាមធ្វើការនោះ សម្រាប់ខ្លួនឯង យើងនឹងបរាជ័យទាំងស្រុង។ យើងត្រូវចាប់ផ្តើមដោយទទួលយកការពិត ដែលព្រះគ្រីស្ទបាន សម្រេចការនេះដល់យើង។ បន្ទាប់មក លោកប៉ូលបន្តថា:

> «ប៉ុន្តែ តើបទគម្ពីរចែងដូចម្តេច? គឺចែងថា: ព្រះបន្ទូលនៅក្បែរអ្នក នៅក្នុងមាត់អ្នក ហើយនៅក្នុងចិត្តអ្នក ផង (នោះគឺ ព្រះបន្ទូលនៃជំនឿ ដែលយើងប្រកាស)។ ព្រោះ បើមាត់អ្នកប្រកាសថា ព្រះយេស៊ូវជា ព្រះអម្ចាស់ ហើយជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យព្រះអង្គមានព្រះជន្មរស់ពីស្លាប់ឡើងវិញ នេះអ្នកនឹង បានសង្គ្រោះ។ ដ្បិតយើងបានសុចរិតដោយមានចិត្តជឿ ហើយបានសង្គ្រោះដោយមាត់ប្រកាសប្រាប់។» (RKOV)

ដូច្នេះ លោកអ្នកឃើញហើយថា មានលក្ខខណ្ឌសាមញ្ញ ហើយប្រកបដោយហេតុផលពីរ ដើម្បីឲ្យបាន ចូលទៅក្នុងសេចក្តីសង្គ្រោះ ជាសេចក្តីសង្គ្រោះដែលសម្រេចបានរួចហើយដល់យើង ដោយការសុគត និងការរស់ ឡើងវិញរបស់ព្រះយេស៊ូ។ ទីមួយទាក់ទងនឹងចិត្ត ហើយទីពីរ ទាក់ទងនឹងមាត់។ ជាមួយចិត្តរបស់យើង យើង ត្រូវតែជឿថា ព្រះបានប្រោសព្រះយេស៊ូវឲ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ។ យើងត្រូវជឿលើការរស់ឡើងវិញ។ អ្នកដែលមិនជឿលើការរស់ឡើងវិញរបស់ព្រះយេស៊ូវ អ្នកនោះមិនអាចរីករាយនឹងការរាប់ជាសុចរិត ដែលរួច ពីបន្ទុកបាបបានឡើយ ព្រោះការនេះ អាស្រ័យលើការរស់ពីសុគតឡើងវិញរបស់ព្រះអង្គ និងការជឿរបស់យើង លើការរស់ពីស្លាប់ឡើងវិញរបស់ព្រះអង្គ។ ដូច្នេះ លក្ខខណ្ឌទីមួយ គឺយើងត្រូវតែជឿក្នុងចិត្តថា ព្រះបានប្រោស ព្រះយេស៊ូវឲ្យរស់ពីស្លាប់ឡើងវិញ។

ប៉ុន្តែ ត្រឹមការនោះមិនទាន់គ្រប់គ្រាន់ទេ។ លក្ខខណ្ឌទីពីរ ទាក់ទងនឹងមាត់។ យើងត្រូវតែប្រកាសចេញ ដោយមាត់របស់យើងថា ព្រះយេស៊ូវជាព្រះអម្ចាស់។ យើងត្រូវទទួលស្គាល់ថាព្រះអង្គទ្រង់ជាម្ចាស់ ហើយ មិនមែនត្រឹមតែភាពជាម្ចាស់ជារួមនៅលើចក្រវាឡទាំងមូលតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រកាសទទួលស្គាល់ដោយឡែកថា ព្រះអង្គជាម្ចាស់នៅក្នុងជីវិតរបស់យើងផ្ទាល់។ នោះគឺជាការប្រគល់ឆន្ទៈផ្ទាល់របស់យើងឲ្យចុះចូល ចំពោះព្រះអង្គ ប្រគល់ខ្លួនយើងឲ្យចុះចូលចំពោះព្រះអង្គ គឺជាកិច្ចការនៃការប្តូរផ្តាច់មួយ ចំពោះព្រះយេស៊ូវ ដែលព្រះអង្គត្រូវតែមានភាពជាម្ចាស់លើលោកអ្នក។ អ្នកខ្លះជឿនៅក្នុងចិត្ត ប៉ុន្តែគេមិនដែលធ្វើការប្តូរផ្តាច់ ហើយពួកគេមិនដែលបញ្ចេញពាក្យប្តូរផ្តាច់របស់ខ្លួន ចំពោះព្រះអង្គសោះ។

ដូច្នេះ ប្រសិនបើលោកអ្នកជាម្នាក់ក្នុងចំណោមអ្នកទាំងនោះ ខ្ញុំចង់ជួយគំនិតលោកអ្នកថា សូមលោកអ្នក ឈានមួយជំហានទៀត គឺសូមចាប់ផ្តើមជំហានទីពីរ។ ប្រហែលជាលោកអ្នកជឿនៅក្នុងចិត្តហើយថា ព្រះ បានប្រោសព្រះយេស៊ូវឲ្យរស់ពីស្លាប់ឡើងវិញ។ លោកអ្នកប្រហែលជាប្រកាសពាក្យនោះច្រើនដងរួចមកហើយ នៅក្នុងព្រះវិហារ។ ប៉ុន្តែ តើលោកអ្នកបានទុកដាក់ខ្លួនទាំងស្រុងឲ្យព្រះអង្គធ្វើជាម្ចាស់ ហើយតើលោកអ្នក បានទទួលស្គាល់ព្រះអង្គ ថាជាព្រះអម្ចាស់ ចេញពីមាត់របស់លោកអ្នកដែរឬទេ? លោកអ្នកឃើញហើយ ជំនឿ របស់យើងត្រូវតែប្រកាសចេញជាសាធារណៈ ដោយខ្លួនឯងផ្ទាល់ នូវអ្វីដែលយើងជឿនៅក្នុងចិត្ត។ នោះហើយ ជាកូនសោសំខាន់ដែលបើកទ្វារចូលទៅកាន់សេចក្តីសង្គ្រោះ។ ដោយចិត្ត គឺជឿថា ព្រះបានប្រោសឲ្យព្រះយេស៊ូវ មានព្រះជន្មរស់ឡើងវិញ រួចប្រកាសដោយមាត់លោកអ្នកថា ព្រះយេស៊ូវ ទ្រង់ជាព្រះអម្ចាស់ ហើយបទគម្ពីរចែង ថា «នោះអ្នកនឹងបានសង្គ្រោះ»។

យើងអស់ពេលសម្រាប់ថ្ងៃនេះហើយ ហើយខ្ញុំនឹងវិលមកជួបជាមួយលោកអ្នកជាថ្មីម្តងទៀតនៅថ្ងៃស្អែក តាមពេលវេលាកំណត់។ ថ្ងៃស្អែក ខ្ញុំនឹងចែកចាយពីរបៀបដែលជ័យជម្នះរបស់ព្រះគ្រីស្ទ បញ្ជាក់ពីជ័យជម្នះ របស់យើង លើអស់ទាំងខ្មាំងសត្រូវរបស់យើង ហើយជាពិសេសគឺ ឈ្នះលើសេចក្តីស្លាប់។ សូមកុំខានតាមស្វែងយល់ជាមួយគ្នានៅវគ្គក្រោយ សូមព្រះអម្ចាស់យេស៊ូវទ្រង់ប្រទានពរ។

ផតខាស
ប្រតិចារិក: RP-R109-102-KHM
បច្ចុប្បន្នភាពចុងក្រោយ: 28 Nov 2026
គេហទំព័រ: Derekprince.com/km/resources

